**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**


**នាយកក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប**

លេខបញ្ជីពាណិជ្ជកម្ម៖ Co. ៥៤៤៨ KH/២០០១

លេខអត្តសញ្ញាណសហគ្រាសក្នុង ប.ស.ស.៖ ១០០០ ៦៥៧៥

លេខគណនីធនាគារ៖ ១៨០០.០១.០៧៥៨៧៤.១៤

អាសយដ្ឋាន ៖ ផ្ទះលេខ៥០, ផ្លូវ២១៤, សង្កាត់បឹងរាំង, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ

ទូរសព្ទលេខ៖ ០២៣ ២២២ ០០១/០១៥ ៦១២ ៧៤៤ Email៖ info@envirocam.com.kh


## កិច្ចព្រមព្រៀងអំពីនីតិវិធីទូទាត់ជាមួយកម្មករនិយោជិត

**យោង៖** សេចក្តីណែនាំរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លេខ០៤៥/២០ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០ ស្តីពីនីតិវិធីព្យួរកិច្ចសន្យាការងារតាមប្រព័ន្ធស្វ័យកម្ម

សេចក្តីដូចមានចែងក្នុងយោងខាងលើ ខ្ញុំសូមជម្រាបជូន **លោកប្រធានសហជីព និងកម្មករនិយោជិតទាំងអស់**មេត្តាជ្រាបថាដោយសារតែមានការកាត់បន្ថយតម្រូវការសេវាកម្មផ្នែកសម្អាតពីព្រលានយន្តហោះអន្តរជាតិភ្នំពេញ យ៉ាងច្រើនសន្ធឹកសន្ធាប់ក្នុងកំឡុងពេលនៃការរីករាលដាលនៃជម្ងឺកូវីដ១៩នេះ ដូច្នេះក្រុមហ៊ុនអេច ស៊ី ស៊ី គ្រុប ប្រចាំនៅព្រលានយន្តហោះអន្តរជាតិភ្នំពេញនិងសៀមរាបនឹងព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ២៣៥នាក់ ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន៧៦១នាក់ ដែលរយៈពេល០២ខែ ដោយគិតចាប់ពីថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២០។

ដើម្បីជាការចែករំលែកដល់កម្មករនិយោជិតដទៃទៀតឲ្យមានប្រាក់ចំណូលខ្លះ ក្រុមហ៊ុនអេច ស៊ី ស៊ី គ្រុបនឹងអនុញ្ញាតឲ្យមានការធ្វើការងារវិលជុំ ដោយប្តូរវេនគ្នាម្តងម្នាក់ ហេតុនេះប្រាក់ឈ្នួលត្រូវគិតទៅតាមចំនួនថ្ងៃជាក់ស្តែងដែលកម្មករនិយោជិតម្នាក់ៗធ្វើការ។ ក្រុមហ៊ុន(អេច ស៊ី ស៊ី)បាននឹងកំពុងបញ្ជូនបុគ្គលិកចំនួន៣០នាក់ទៅស្ថានីយ៍ផ្សេងៗទៀត ដើម្បីឲ្យកម្មករនិយោជិតទទួលបានការងារធ្វើ ដោយផ្តល់ជូនថ្លៃធ្វើដំណើរផងដែរ។ យើងខ្ញុំក៏សូមជម្រាបជូនលោកប្រធានសហជីព និងកម្មករនិយោជិតទាំងអស់មេត្តាជ្រាបផងដែរថា ការកាត់បន្ថយតម្រូវការសេវាកម្មសម្អាតនេះទៀតសោត ព្រលានយន្តហោះអន្តរជាតិទាំងពីរក៏បានកាត់បន្ថយប្រាក់ចំណូលពីក្រុមហ៊ុនអេច ស៊ី ស៊ី ផងដែរ ដោយព្រលានយន្តហោះអន្តរជាតិភ្នំពេញបានកាត់បន្ថយប្រាក់ចំណូលជាង ៧៥% និងព្រលានយន្តហោះអន្តរជាតិសៀមរាបបានកាត់បន្ថយប្រាក់ចំណូលជាង៩០% ។ ដូច្នេះក្រុមហ៊ុនពុំមានលទ្ធភាពបង់ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ជូនកម្មករនិយោជិតដែលព្យួរកិច្ចសន្យាការងារបានទេ ។ ទោះជាយ៉ាងក៏ដោយក្រុមហ៊ុន(អេច ស៊ី ស៊ី) នៅតែរក្សាទំនាក់ទំនងល្អជាមួយកម្មករនិយោជិត និងទទួលពួកគាត់ឲ្យត្រលប់មកធ្វើការងារវិញ នៅពេលណាដែលស្ថានភាពល្អប្រសើរឡើង។

រាជធានីភ្នំពេញ ថ្ងៃទី២៩...... ខែកក្កដា ឆ្នាំ២០២០ | រាជធានីភ្នំពេញ ថ្ងៃទី២៩...... ខែកក្កដា ឆ្នាំ២០២០

**តំណាងសហជីព** | **ភាគីខាងក្រុមហ៊ុន**

អេច ស៊ី ស៊ី គ្រុប
HCC Group
Co., Ltd.

29/07/20